# សេចក្តីណែនាំអំពីថ្នាំ Lagevrio

| | |
|---|---|
| ឈ្មោះផលិតផល | គ្រាប់ថ្នាំ Lagevrio |
| គ្រឿងផ្សំ / ខ្លឹមសារ | Nirmatrelvir 200mg (ក្នុង1គ្រាប់) |
| ការពិពណ៌នា | ថ្នាំគ្រាប់ ពណ៌ទឹកក្រូច |
| ថ្នាំគ្រាប់ ពណ៌ទឹកក្រូច | • មួយថ្ងៃ2ដង លេបថ្នាំ Nirmatrelvir ២គ្រាប់ និងថ្នាំ Ritonavir 2គ្រាប់ រួមគ្នា ២ដង ក្នុងមួយថ្ងៃ រយៈពេល៥ថ្ងៃ សរុប ១០ដង<br>• ចាប់ផ្តើមព្យាបាល ក្រោម ៥ថ្ងៃ ក្រោយចេញរោគសញ្ញា និង ទទួលបានលទ្ធផលវិជ្ជមានជំងឺ COVID-19<br>• ប្រសិនបើអ្នកកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ ពេលកំពុងប្រើថ្នាំ វាអាស្រ័យលើ បុគ្គលិកពេទ្យក្នុងការសម្រេចចិត្តថា តើត្រូវបន្តប្រើថ្នាំ ឬអត់។ |
| ប្រសិទ្ធភាព / ផលប៉ះពាល់ | ការព្យាបាលអ្នកជំងឺ COVID-19 ពេញវ័យ មានរោគសញ្ញាធ្ងន់ធ្ងរ កម្រិតស្រាល និងមធ្យម ក្នុងការវិវត្តទៅជារោគសញ្ញាធ្ងន់ធ្ងរ មានហានិភ័យខ្ពស់។<br>ទោះបីជាយ៉ាងណាក៏ដោយ វាអាចប្រើបាន សម្រាប់អ្នកជំងឺ ដែលមិនអាច ប្រើថ្នាំព្យាបាលជំងឺ COVID-19 ឬក៏អ្នកជំងឺ COVID-19 ដែលមិនមាន ការព្យាបាលសមស្របផ្សេងទៀត។ |
| របៀបរក្សាទុក | រក្សាទុកនៅកន្លែង មានសីតុណ្ហភាព 15℃~30℃ |

## ♣ គ្រាប់ថ្នាំ Lagevrio តើប្រើយ៉ាងម៉េច?

**ប្រើ ម្តង ៤គ្រាប់, ១ថ្ងៃ ២ដង រយៈពេល ៥ថ្ងៃ -> ប្រើ សរុប ១០ដង**




• អាចលេបបាន មិនគិតថាបាយរួចឬអត់ទេ, គឺសំខាន់ថា ប្រើប្រាស់ជាប់គ្នា មិនឈប់ និងព្យាបាលជាស្ទះស្មើរ រយៈពេល ៥ថ្ងៃ សរុប ១០ដង។

• ត្រូវតែលេប ទាំងមូល គ្រាប់ថ្នាំ មិនត្រូវបើក ឬកុំបំបែក ឬកុំទំពារ។

• សូមកំណត់ពេលម៉ោង ដែលងាយក្នុងលេបថ្នាំ និងមិនភ្លេចលេប តាមម៉ោងកំណត់ ដោយត្រូវតែលេប ក្នុងចន្លោះ ១២ម៉ោង ប្រចាំថ្ងៃ ចាប់ពីថ្ងៃដំបូង។ ឧទាហរណ៍) ព្រឹក ម៉ោង ៩ / រហូតត្រឹម ពេលល្ងាច ម៉ោង៩

## ♣ ករណីភ្លេចលេបថ្នាំ តើត្រូវធ្វើដូចម៉េច?

| ① ករណីភ្លេចលេបថ្នាំ ក្រោម ១០ម៉ោង | ② ករណីភ្លេចលេបថ្នាំ លើស ១០ម៉ោងឡើង |
|---|---|
| • លេបភ្លាមៗ ពេលនឹកឃើញ ហើយលេបបន្ទាប់តាមម៉ោងកំណត់ដដែរវិញ<br>• ក្រោយមក សូមរក្សាម៉ោង លេបថ្នាំដដែល | •<br>រំលងកម្រិតថ្នាំដែលខកខានហើយលេបថ្នាំធម្មតាតាមម៉ោងកំណត់បន្ទាប់<br>• ក្រោយមក សូមរក្សាម៉ោង លេបថ្នាំដដែល |
| (សូមកុំលេបថ្នាំ ២ដងក្នុងពេលតែមួយឲ្យសោះ) | |

## ♣ ប្រើគ្រាប់ថ្នាំ Lagevrio តើមានចំណុចប្រុងប្រយ័ត្ន អ្វីខ្លះ?

1.ប្រតិកម្មអាល្លែហ្ស៊ី កំឡុងពេលកំពុងប្រើប្រាស់ ត្រូវបានគេរាយការណ៍ថា ដោយមានសារធាតុប្រតិកម្ម Anaphylaxis នៅក្នុងថ្នាំនេះ។ ប្រសិនបើអ្នកជួបប្រទះនូវសញ្ញា និងរោគសញ្ញានៃប្រតិកម្មអាល្លែហ្ស៊ី ដូចជា (ញ៉័រទ្រូង, ឡើងកន្ទួលរមាស់, ពិបាកដកដង្ហើម ។ល។) ឬប្រតិកម្ម Anaphylaxis បន្ទាប់ពីប្រើថ្នាំនេះ សូមបញ្ឈប់ការប្រើជាបន្ទាន់ ហើយ ជូនដំណឹងទៅស្ថាប័នវេជ្ជសាស្ត្ររបស់អ្នក ដើម្បីចាប់ផ្តើមការ ព្យាបាល សមស្រប។

2.ថ្នាំនេះមិនអាចប្រើចំពោះស្ត្រីមានផ្ទៃពោះទេ ហើយស្ត្រីដែលមានលទ្ធភាព មានកូន ត្រូវតែពិនិត្យឲ្យច្បាស់ថា មិនមានផ្ទៃពោះ ទើបអាចប្រើថ្នាំនេះបាន។ ប្រសិនបើ ករណីអ្នកប្រើថ្នាំនេះ ដោយមិនដឹងថាកំពុងមានផ្ទៃពោះ សូម បញ្ឈប់ការប្រើថ្នាំនេះភ្លាមៗ ហើយសូម ពីគ្រោះជាមួយគ្រូពេទ្យជំនាញ ឬអ្នកអាចទាក់ទងមក MSD Korea (02-331-2000) ដើម្បីសាកសួរ ឬពិគ្រោះជាមួយដោយផ្ទាល់បាន។

3. ក្នុងកំឡុងពេលប្រើថ្នាំនេះ ស្ត្រីដែលមានគម្រោងមានផ្ទៃពោះ កំពុងប្រើ និង ប្រើបាន ៤ថ្ងៃ ចុងក្រោយ គួរតែ ប្រើវិធី ពន្យារកំណើត ប្រកបដោយប្រសិទ្ធភាព ជាមួយបុរស ជាស្វាមី រហូតដល់ ៣ខែ។ លើសពីនេះ ស្ត្រីដែលកំពុងបំបៅកូន ដោយទឹកដោះ អ្នកគួរតែបញ្ឈប់ការបំបៅដោះកូន រហូតដល់ ៤ថ្ងៃ បន្ទាប់ពីការចាក់ថ្នាំចុងក្រោយនេះរួច។

4. ការផ្តល់ថ្នាំ ដល់អ្នកដទៃ ដោយគ្មានការអនុញ្ញាតពីវេជ្ជបញ្ជា ពីវេជ្ជបណ្ឌិតគឺមាន គ្រោះថ្នាក់ខ្លាំងណាស់ ហើយនិងត្រូវផ្តន្ទាទោស តាមច្បាប់ពាក់ព័ន្ធ។ ជាគោលការណ៍

ប្រសិនបើថ្នាំត្រូវបានបញ្ឈប់ការលេប ដោយសារអាការៈ ប្រតិកម្ម ផ្សេងៗ កើតឡើង បន្ទាប់ពីប្រើថ្នាំនេះ ការព្យាបាលនឹងបញ្ឈប់ ហើយថ្នាំដែលសេសសល់ គឺត្រូវបោះចោល។

## ♣ តើមានផលប៉ះពាល់អ្វីខ្លះ ដែលកើតមានឡើង?

| | | |
|---|---|---|
|  |  |  |
| រាគ | ក្អួតចង្អោរ | ស្រវាំង |

* ក្នុងករណីអាការៈផ្សេងៗ អាចមានការប្រើប្រាស់ផ្សេងគ្នា អញ្ជើង សូមទៅប្រឹក្សាជាមួយឱសថស្ថាន ឬក៏មណ្ឌលព្យាបាល ដែលទទួលបានថ្នាំសិន ប្រសិនបើឃើញថា ក្រោយលេបថ្នាំនឹងរួច មានផលប៉ះពាល់។ ឬក៏អាចទទួលការប្រឹក្សាផ្ទាល់ពី វិទ្យាស្ថានគ្រប់គ្រងសុវត្ថិភាពឱសថកូរ៉េ តាមរយៈទូរស័ព្ទលេខ (1644-6223) ពេលមានផលប៉ះពាល់។

- សម្រាប់ពត៌មានបន្ថែមសូមចូលឆែកក្នុងគេហទំព័រមណ្ឌលសុខភាពតាមតំបន់ ឬក៏ឆែកក្នុងគេហទំព័រ មន្ទីរគ្រប់គ្រងបង្ការជំងឺកូរ៉េ (www.kdac.or.kr) ករណីមានចម្ងល់បន្ថែម។

대한약사회 THE KOREAN PHARMACEUTICAL ASSOCIATION

대한약사회 환자안전약물관리본부

한국의약품안전관리원